# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 17 – Speaking up
## មេរៀនទី១៧៖ ការបញ្ចេញទស្សនៈផ្ទាល់ខ្លួន

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

តួអង្គ

Rocky:
រ៉ុកឃី ៖ និស្សិតអន្តរជាតិ។

Angel:
អែនជល ៖ និស្សិតអន្តរជាតិ។

Katie:
ខេតធី ៖ និស្សិតអន្តរជាតិ។

Marion:
មារៀន ៖ គ្រូបង្រៀន។

Ralph:
រ៉ាលហ្វ ៖ និស្សិតបុរស។

សាច់រឿង

ខេតធីមានការលំបាកក្នុងការបញ្ចេញទស្សនៈផ្ទាល់ខ្លួននៅក្នុងចំណោមក្រុមសិស្ស។

ព័ត៌មាន – ការបញ្ចេញគំនិត – ឃ្លាសាមញ្ញមួយចំនួន

ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនសម្រាប់បង្ហាញអំពីរបៀបបញ្ចេញយោបល់ផ្ទាល់ខ្លួន។

ឃ្លាសាមញ្ញសម្រាប់ការចាប់ផ្តើម

**I think that** everyone should have the right to join a union.

**ខ្ញុំគិតថា** មនុស្សគ្រប់គ្នា គួរមានសិទ្ធិចូលរួមក្នុងសហជីព។

**In my opinion** health services should be provided free.

**តាម**យោបល់**របស់ខ្ញុំ** សេវាសុខភាពគួរផ្តល់ជូនដោយឥតគិតថ្លៃ។

**If you ask me**, the cost of dental services is way too high.

**ប្រសិនបើអ្នកសួរខ្ញុំ (ខ្ញុំគិតថា)** ថ្លៃសេវា(ថែទាំ)ធ្មេញ មានតម្លៃថ្លៃខ្លាំងណាស់។


© RadioAustralia/AMES 2008

<u>គំនិតយោបល់ជាក់ច្បាស់</u>

**I definitely think that** honesty should be rewarded, not punished.

**ខ្ញុំពិតជាគិតថា** ភាពស្មោះត្រង់ គួរទទួលបានការលើកទឹកចិត្ត មិនមែនការដាក់ពិន័យនោះទេ។

**I strongly believe** that capital punishment is inhumane.

**ខ្ញុំមានជំនឿមុតមាំថា** ការកាត់ទោសប្រហារជីវិត គឺជាអំពើអមនុស្សធម៌។

<u>ការបញ្ជាក់ភាពប្រាកដប្រជា</u>

**In fact,** Melbourne has the second largest Greek population outside of Athens.

**តាមការពិត** ទីក្រុងមែលប៊ិន មានប្រជាជនក្រិចច្រើនលំដាប់ទីពីរ បន្ទាប់ពីទីក្រុង Athens។

**Actually,** this report shows that more young people are experiencing hearing loss.

**តាមពិត** របាយការណ៍នេះ បង្ហាញថា មានយុវវ័យច្រើនឡើងៗ កំពុងតែមានបញ្ហាបាត់បង់សោតវិញ្ញាណ(ថ្លង់)។

<u>ការបង្ហាញពីភាពមិនច្បាស់លាស់</u>

**It seems that** the rich are getting richer.

តាមមើលទៅ អ្នកមាន គឺកាន់តែមានទៅៗ។

**There's probably a good argument for** raising nurses' wages.

ទំនងជាមានចំណុចតវ៉ា/ការវែកញែកដ៏ល្អមួយ សម្រាប់ការដំឡើងបៀវត្សរ៍ដល់គិលានុបដ្ឋាក។

**<u>ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា</u>**

| | |
|---|---|
| To wind down a discussion<br>បញ្ចប់ការពិភាក្សាតាមសម្រួល | បញ្ចប់ការពិភាក្សាតាមសម្រួល<br>(គឺដោយមិនប្រញាប់ប្រញាល់)។ |
| A load of rubbish<br>ផ្ដេសផ្ដាសមិនបានការ | មិនពិត។ មិនគួរឱ្យជឿ។ |

ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008

## EXERCISES

## លំហាត់

១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក៖

| | | |
|---|---|---|
| article (newspaper) | discussion | evidence |
| expert | extended | harmful |
| (to) over-react | period (of time) | possibility |
| research | sign | (to) suffer |
| tinnitus | (to) bother | volume |

២. ការហាត់រៀនភាសា៖ លំហាត់គំរូ ការធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best completes each sentence.

ចូរជ្រើសពាក្យដែលសមស្របបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។

សូមគូសសញ្ញាខ្វែងនៅក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ។ឧទារហណ៍៖ ☒

**MP3 players and hearing loss**

Did you know that since MP3 players have _____1___ popular, there have been more reported incidents of hearing loss caused _____2___ listening to excessively loud music? Did you also know that if you have ringing in your ears after you turn your MP3 player off, it's a sign that your music is too loud? Another sign that your MP3 player music is too loud is if a bystander can hear it _____3___ you have the headphones on. To _____4___ hearing loss, keep the volume of your player down. You don't have to lose sound quality. Just download bigger files _____5___ better sound.

1. ☐ be ☐ become ☐ became ☐ becoming


© RadioAustralia/AMES 2008

| | | | | |
|---|---|---|---|---|
| 2 | ☐ by | ☐ from | ☐ with | ☐ to |
| 3. | ☐ while | ☐ even | ☐ so | ☐ because |
| 4 | ☐ enable | ☐ conclude | ☐ avoid | ☐ avoiding |
| 5 | ☐ that | ☐ whose | ☐ for | ☐ which |

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

សូរសំឡេង /f/ ៖ សូមហាត់ពត់អណ្ដាតនិយាយពាក្យលំបាកខាងក្រោមនេះ ដោយបញ្ចេញសំឡេងឲ្យបានឮៗ ៖

"I fear for the firemen who often fight fires."

## ៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍

| | |
|---|---|
| ព័ត៌មាន៖ ក្រេបយកអត្ថប្រយោជន៍ពីការបង្រៀនជាក្រុមតូចៗ | http://www.pb.unimelb.edu.au/CampusMaps/Parkville.pdf |
| ការបញ្ចេញយោបល់។ | http://www.languageproject.co.uk/learn_english/10_key_expressions.php?pageID=25&level=2 |

ចម្លើយលំហាត់ទី 2: 1) become 2) by 3) while 4) avoid 5) for


© RadioAustralia/AMES 2008